**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កំណត់ហេតុ

## ព្យួរកិច្ចសន្យាការងារ ក្រុមហ៊ុន អេមិណិន ហ្គាម៉ិន(ខេមបូឌា) លីមីធីត

ឆ្នាំពីរពាន់ម្ភៃ ខែសីហា ថ្ងៃទី ១៥មានការបើកកិច្ចប្រជុំនៅក្រុមហ៊ុន អេមិណិនហ្គាម៉ិន(ខេមបូឌា)លីមីធីត ដែលមានទីតាំងស្ថិតនៅ ផ្លូវលេខ ២១ ភូមិ ព្រែកថ្មី ឃុំ ទឹកវិល ស្រុក ស្អាង ខេត្ត កណ្តាល។

ក្រោមអធិបតីភាពលោក PENG HAO JUN ជានាយកក្រុមហ៊ុន និងលោកស្រី ឈុន អ៊ី ប្រធានផ្នែករដ្ឋបាលបានពិនិត្យអំពីបញ្ហាក្រុមហ៊ុនជួបវិបត្តិ ខ្វះវត្ថុធាតុដើមនឹងភ្ញៀវបញ្ជាទិញ ដោយសារជំងឺរលាកផ្លូវដង្ហើម COVID-19ធ្ងន់ធ្ងរ ដូច្នេះហើយទើបក្រុមហ៊ុនឈានទៅដល់ព្យួរកិច្ចសន្យាការងារកម្មករនិយោជិត ចំនួន ២៦៤ នាក់ ស្រី ២៣៩ នាក់ ប្រុស ២៥ នាក់ ដោយការព្យួរកិច្ចសន្យាការងារគឺគិតចាប់ពីថ្ងៃទី ៣០ សីហា ឆ្នាំ២០២០ រហូតដល់ ថ្ងៃទី២៨ ខែ តុលា ឆ្នាំ ២០២០ រយះពេល ៦០ថ្ងៃ។

ក្នុងរយះពេលព្យួរនេះ ក្រុមហ៊ុននឹងបើកប្រាក់ឧបត្ថម្ភ៣០ដុល្លា ក្នុង១ខែម្តង ដោយត្រូវបើកនៅរៀងរាល់ខែ នៃថ្ងៃ ទី ០៧ នៃខែនិមួយៗ។

## សមាសភាពចូលរួម

**-តំណាងនិយោជក**

-លោក PENG HAO JUN នាយកក្រុមហ៊ុន

-លោកស្រី ឈុន អ៊ី ប្រធានផ្នែករដ្ឋបាល

**-តំណាងកម្មករនិយោជិត**

-លោកស្រី រ៉ាប់ មិថុនា ប្រធានសហជីព កម្ពុជា-អាស៊ាន នៃក្រុមហ៊ុនអេមិណិនហ្គាម៉ិន (ខេមបូឌា) លីមីធីត

-លោកស្រី ស្រេង រ៉ាន់នី ជាលេខាធិការ សហជីពកម្ពុជា-អាស៊ាននៃក្រុមហ៊ុនអេមិណិន ហ្គាម៉ិន(ខេមបូឌា)លីមីធីត

លោកស្រី រ៉ាប់មិថុនាប្រធានសហជីព កម្ពុជា-អាស៊ាន នៃក្រុមហ៊ុនអេមិណិន ហ្គាម៉ិន(ខេមបូឌា)លីមីធីត មានប្រសាសន៍ថា ក្រុមហ៊ុន ពិតជាគ្មានការងារធ្វើមែន ព្រោះគ្មានអ្នកបញ្ជាទិញ ដោយសារជំងឺរលាកផ្លូវដង្ហើម COVID-19 ដូច្នេះនាងខ្ញុំមិនជំទាស់ការព្យួរកិច្ចសន្យាការងារនេះទេ។

-លោកស្រី ហ៊ាង ស្រីនាង ជាតំណាងកម្មករ នៃក្រុមហ៊ុនអេមិណិន ហ្គាម៉ិន(ខេមបូឌា)លីមីធីត មានប្រសាសន៍ថា បច្ចុប្បន្ននេះក្រុមហ៊ុន ពិតជាជួបបញ្ហាវិបត្តិ ផលិតផលមិនអាចនាំចេញបានដោយសារ ជំងឺរលាកផ្លូវដង្ហើម COVID-19 ធ្ងន់ធ្ងរ ដូច្នេះនាងខ្ញុំឯកភាពលើការព្យួរកិច្ចសន្យាការងារនេះ ព្រោះក្រុមហ៊ុនពិតជាគ្មានការងារធ្វើមែន។

-ប្រធានក្រុមគ្រប់ផ្នែកទាំងអស់បានចូលរួមកិច្ចប្រជុំ ហើយបានឯកភាពទាំងអស់គ្នារួចផ្តិតមេដៃទុកជាភស្តុតាង។

-លទ្ធផលពិភាក្សា

-លោក PENG HAO JUN នាយកក្រុមហ៊ុន តំណាងកម្មករ និងប្រធានសហជីពមូលដ្ឋានបានឯកភាពគ្នាលើការព្យួរកិច្ចសន្យាការងារនេះ ព្រោះក្រុមហ៊ុនពិតជាទទួលរងបញ្ហា ខ្វះវត្ថុធាតុដើម ខ្វះអ្នកបញ្ជាទិញបណ្តាលអោយកម្មករនិយោជិតពិតជាគ្មានការងារធ្វើមែន ហើយថែមទាំងផលិតផលមិនអាចនាំចេញបានប្រាកដមែន។

កិច្ចប្រជុំបានចប់សព្វគ្រប់នៅវេលាម៉ោង ១០និង45នាទីព្រឹក ថ្ងៃខែឆ្នាំដដែល។

ថ្ងៃច័ន្ទ ១១រោច ខែ ស្រាពណ៍ ឆ្នាំ ជូត ឯកស័ក ព.ស២៥៦៤
ធ្វើនៅ កណ្តាល,ថ្ងៃទី១៥ ខែសីហា ឆ្នាំ ២០២០

**នាយកក្រុមហ៊ុន**

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
អេមីណិន ហ្គាមិន (ខេមបូឌា) លីមីធីត
EMINENT GARMENT (CAMBODIA) LIMITED
KINGDOM OF CAMBODIA

PENG HAO JUN

ស្នាមមេដៃតំណាងកម្មករ សហជីព និងប្រធានក្រុម

១-វ៉ាប់ មិថុនា
២-ឆេង សុធានី
៣-ពន្លក ស្រីអ៊ឹម
៤-ណុប ស៊ីនឿន
៥-ខុម ស្រីភ័ស្ត
៦-ហ៊ាង ស្រីនាង
៧-ហ៊ាន ចន្ទី
៨-ទ្បោ សំអុល
៩-ហ៊ាង ស្រីពៅ
១០-គង សុខគាង
១១-ម៉ន ប៉ា
១២-រស់ សាលាភ